**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧.០១៧.០០២ ប.ក.ព.ក.ម

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## សិក្ខាសាលាស្តីពីការអភិវឌ្ឍផែនការសកម្មភាពក្នុងការអនុវត្តគម្រោងដាក់បញ្ចូលចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះទូទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

រាជធានីភ្នំពេញ ថ្ងៃពុធ ទី២៧ ខែកញ្ញា ឆ្នាំ២០១៧

ធនាគារជាតិនៃកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា ក្រោមកិច្ចសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី អង្គការ Good Return និង World Education Cambodia បានរៀបចំសិក្ខាសាលាស្តីពីការអភិវឌ្ឍផែនការសកម្មភាពក្នុងការអនុវត្តគម្រោងដាក់បញ្ចូលចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះទូទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា។

ផុសចេញពីគោលបំណងថ្នាក់ជាតិក្នុងការបង្កើនចំណេះដឹងផ្នែកហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា គម្រោងដាក់បញ្ចូលអក្ខរកម្មផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីចំណេះទូទៅរបស់ក្រសួងអប់រំ នឹងផ្តល់ឱកាសឲ្យកុមារកម្ពុជាអាចទទួលបានការអប់រំផ្នែកហិរញ្ញវត្ថុចាប់ពីកុមារភាពទៅ។ សិស្សានុសិស្សនឹងទទួលបានការអប់រំអំពីគន្លឹះសំខាន់ៗ ដែលទាក់ទងទៅនឹងការសន្សំ ការខ្ចីប្រាក់ និងការគ្រប់គ្រងហិរញ្ញវត្ថុនៅក្នុងកម្មវិធីសិក្សាទូទៅ។

"ការអប់រំផ្នែកហិរញ្ញវត្ថុ មានសារៈសំខាន់ក្នុងការអភិវឌ្ឍសង្គមជាតិ ព្រោះការយល់ច្បាស់ពីផលិតផលហិរញ្ញវត្ថុ ការជ្រើសរើស និងការប្រើប្រាស់ផលិតផល ទាំងនោះបានត្រឹមត្រូវ អាចការពារអតិថិជនឲ្យផុតពីការកេងបន្លំ និងបំណុលវ័ន្តក។ លើសពីនេះទៅទៀត ការអប់រំផ្នែកហិរញ្ញវត្ថុ គួរត្រូវបានផ្តល់ជូនកុមារកម្ពុជាគ្រប់រូបចាប់ពីអាយុតិចទៅ ដើម្បីឲ្យពួកគេមានមូលដ្ឋានគ្រឹះក្នុងការទទួលបាន និងប្រើប្រាស់សេវាហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាពខ្ពស់នៅថ្ងៃអនាគត" នេះបើយោងតាមប្រសាសន៍របស់លោកជំទាវ ជា សិរី អគ្គនាយកបច្ចេកទេស ធនាគារជាតិនៃកម្ពុជា។

សិក្ខាសាលាខាងលើ នឹងមានការចូលរួមពីសំណាក់អ្នកជំនាញពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គណៈកម្មការមូលបត្រកម្ពុជា ក្រសួង-ស្ថាប័នពាក់ព័ន្ធមកពីវិស័យហិរញ្ញវត្ថុ វិស័យអប់រំ និងដៃគូអភិវឌ្ឍន៍ ដើម្បីកំណត់ពី

តម្រូវការសមត្ថភាពផ្នែកហិរញ្ញវត្ថុចាំបាច់នៅក្នុងបរិបទប្រទេសកម្ពុជា និងពិភាក្សាគោលការណ៍ណែនាំសម្រាប់បញ្ចូលការអប់រំផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាជាតិ។

លទ្ធផលដែលទទួលបានពីសិក្ខាសាលានឹងផ្តល់នូវផែនទីមគ្គុទេសន៍សម្រាប់អនុវត្តកម្មវិធីសិក្សាដែលបានស្នើឡើងនៅក្នុងដំណាក់កាលទី២នៃគម្រោង។

លោកបណ្ឌិត ម៉ុក សារ៉ុម អគ្គនាយករងអប់រំ និងជាប្រធានលេខាធិការដ្ឋានកែលម្អកម្មវិធីសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា បានមានប្រសាសន៍ថា៖ “**ការគ្រប់គ្រងហិរញ្ញវត្ថុយ៉ាងគត់មត់ ជាដំណើរឆ្ពោះទៅរកស្ថិរភាពសង្គមនិងបរិយាប័ន្ន។** ដើម្បីកសាងសង្គមនេះ ការដាក់ផែនការហិរញ្ញវត្ថុជាកត្តាចំបាច់បំផុតដែលត្រូវបណ្តុះដល់សិស្សានុសិស្សតាំងពីកុមារភាពឡើងទៅ។ ការអប់រំផ្នែកហិរញ្ញវត្ថុដល់កុមារ ជាទស្សនាទានដែលធ្វើឲ្យពួកគាត់ត្រៀមខ្លួនជាស្រេចក្នុងការនាំជីវិតឆ្ពោះទៅរកចីរភាពផ្នែកហិរញ្ញវត្ថុ ដោយបណ្តុះនិស្ស័យការសន្សំសំចៃនិងការប្រើប្រាស់លុយដ៏ត្រឹមត្រូវតាំងតែពីកុមារភាព។ ដូច្នេះ ការដាក់ផែនការហិរញ្ញវត្ថុ ចាត់ទុកជាគោលគំនិតសំខាន់បំផុតដែលធ្វើឲ្យជីវិតអាចដំណើរការបានយ៉ាងរលូនក្នុងវ័យនីមួយៗយ៉ាងប្រសើរ និងមានសុខភាពផ្នែកហិរញ្ញវត្ថុយ៉ាងល្អ។ ដូចពាក្យចាស់ពោលថា ដាំដុះក្នុងសាលា ផ្លែផ្កាក្នុងសង្គម។”

លោក Shane Nichols នាយកប្រតិបត្តិរបស់អង្គការ Good Return មានប្រសាសន៍ថា៖ “អង្គការ Good Return មានសេចក្តីរីករាយដែលបានសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ក្នុងការគាំទ្រធនាគារជាតិនៃកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា ដើម្បីនាំយកនូវចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅដល់ថ្នាក់រៀនរបស់សិស្សានុសិស្សកម្ពុជាទូទាំងប្រទេស និងដើម្បីលើកកម្ពស់ចំណេះដឹងនិងលទ្ធភាពរបស់យុវជនវ័យក្មេងក្នុងការគ្រប់គ្រងហិរញ្ញវត្ថុរបស់ពួកគេនាពេលអនាគត។”

គម្រោងដាក់បញ្ចូលចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះទូទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា នឹងក្លាយជាយន្តការក្នុងការបណ្តុះអាកប្បកិរិយាវិជ្ជមានផ្នែកហិរញ្ញវត្ថុ និងការគ្រប់គ្រងប្រាក់សម្រាប់សិស្សានុសិស្សទូទាំងប្រទេសកម្ពុជា។៸